**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០១៥/២៥ ន. គ. ស /សរ.ស.ណ.

ថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមេសា គ.ស.២០២៥

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការប្រឡងប្រជែងជ្រើសរើសបេក្ខជន បេក្ខនារី ជាមន្ត្រីលក្ខន្តិកៈនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យចូលបម្រើការងារ នៅនិយ័តករគណនេយ្យនិងសវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សូមជូនដំណឹងដល់និស្សិត និងសាធារណជនទូទៅឱ្យបានជ្រាបថា **ន.គ.ស.** នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជន បេក្ខនារីទាំងពីរភេទ ឱ្យចូលបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម ចំនួន ១៥រូប ដូចខាងក្រោម៖

### ១.លក្ខខណ្ឌនៃការជ្រើសរើស

### ក.លក្ខខណ្ឌទូទៅ

- ត្រូវមានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឡើងទៅលើជំនាញនីមួយៗ
- ត្រូវមានចំណេះដឹងកុំព្យូទ័រ Microsoft Office
- ចេះភាសាអង់គ្លេសអាចប្រើប្រាស់ជាផ្លូវការបាន
- ត្រូវមានអាយុមិនលើស ៣៥ឆ្នាំ ចំពោះបេក្ខជន បេក្ខនារីដែលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល និងត្រូវមានអាយុមិនលើស ៤៥ឆ្នាំ ចំពោះបេក្ខជន បេក្ខនារីដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គិតត្រឹមថ្ងៃដាក់ពាក្យ
- មានបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញយ៉ាងតិច ០២ឆ្នាំ
- បេក្ខនារីត្រូវបានលើកទឹកចិត្ត
- មានស្មារតីធ្វើការងារជាក្រុម
- មិនធ្លាប់មានទោសពីបទឧក្រិដ្ឋ និងបទមជ្ឈិមណាមួយ
- មានគំនិតឆ្នៃប្រឌិត អត្តចរិកស្លូតបូត ស្មោះត្រង់ អំណត់អត់ធន់ ឧស្សាហ៍ព្យាយាម និងមានការទទួលខុសត្រូវខ្ពស់ក្នុងការងារ។

### ខ. លក្ខខណ្ឌជាក់លាក់

១.នាយកដ្ឋានកិច្ចការទូទៅ (២រូប)

➢ **ជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(១ រូប)**

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬសញ្ញាបត្រជំនាញប្រហាក់ប្រហែល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

- មានចំណេះដឹងស្រាវជ្រាវ ចងក្រងនិងវិភាគទិន្នន័យ
- មានចំណេះដឹងផ្នែកគោលនយោបាយ,យុទ្ធសាស្ត្រ និងផែនការផ្សេងៗ
- អាចពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពការងារទាំងគោលនយោបាយ និងយុទ្ធសាស្ត្រ
- មានភាពជាអ្នកដឹកនាំ ភាពស្ទាត់ជំនាញ និងឆ្នៃប្រឌិតក្នុងការវិភាគនិងដោះស្រាយបញ្ហាជំនាញ ធ្វើផែនការចាត់ចែងនិងគ្រប់គ្រងពេលវេលា ព្រមទាំងមានគំនិតផ្តួចផ្តើមនិងភាពអំណត់ខ្ពស់។

➢ **ជំនាញទំនាក់ទំនងអន្តរជាតិ (១រូប)**

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញទំនាក់ទំនងអន្តរជាតិឬសញ្ញាបត្រ ជំនាញប្រហាក់ប្រហែល
- មានចំណេះដឹងផ្នែកទំនាក់ទំនងជាតិ និងអន្តរជាតិ
- រៀបចំ និងអនុវត្តផែនការសហប្រតិបត្តិការជាមួយអាជ្ញាធរ ឬស្ថាប័នគ្រប់គ្រងវិស័យគណនេយ្យ និងសវនកម្ម នៃបណ្តាលប្រទេសផ្សេងទៀត និងដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធរបស់វិស័យគណនេយ្យនិងសវនកម្ម នៃបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក
- តាមដាន និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ និងដំណើរការវិវត្តជាអន្តរជាតិក្នុងវិស័យ គណនេយ្យនិងសវនកម្ម។

## ២.នាយកដ្ឋានបច្ចេកទេស

➢ **ជំនាញគណនេយ្យនិងសវនកម្ម(៧រូប)**

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញគណនេយ្យនិងសវនកម្ម ឬសញ្ញាបត្រ ជំនាញប្រហាក់ប្រហែល
- សញ្ញាបត្រគណនេយ្យករជំនាញ (ACCA, CPA) ឬសញ្ញាបត្របច្ចេកទេសគណនេយ្យ (CAT) ត្រូវបានលើកទឹកចិត្ត
- មានសមត្ថភាព និងទំនួលខុសត្រូវខ្ពស់ក្នុងការសិក្សាស្រាវជ្រាវ ក៏ដូចជាការបកស្រាយស្តង់ដា គណនេយ្យ ស្តង់ដាសវនកម្ម ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដាពាក់ព័ន្ធ។

## ៣.នាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

➢ **ជំនាញគណនេយ្យនិងសវនកម្ម(៣រូប)**

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញគណនេយ្យនិងសវនកម្ម ឬសញ្ញាបត្រ ជំនាញប្រហាក់ប្រហែល
- សញ្ញាបត្រគណនេយ្យករជំនាញ (ACCA, CPA) ឬសញ្ញាបត្របច្ចេកទេសគណនេយ្យ (CAT) ត្រូវបានលើកទឹកចិត្ត
- មានបទពិសោធន៍ក្នុងការត្រួតពិនិត្យ ឬផ្នែកសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងការរៀបចំ គ្រប់គ្រងទិន្នន័យក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម។
- មានសមត្ថភាពក្នុងការវិភាគ និងការត្រួតពិនិត្យលើគុណភាពសេវាគណនេយ្យនិងសវនកម្ម។

## ៤.នាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព

➢ **ជំនាញគណនេយ្យនិងសវនកម្ម(៣រូប)**

បេក្ខជន បេក្ខនារីត្រូវមានលក្ខណៈសម្បត្តិ និងភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖
- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅលើជំនាញគណនេយ្យនិងសវនកម្ម ឬសញ្ញាបត្រ ជំនាញប្រហាក់ប្រហែល

- សញ្ញាបត្រគណនេយ្យករជំនាញ (ACCA, CPA) ឬសញ្ញាបត្របច្ចេកទេសគណនេយ្យ (CAT) ត្រូវបានលើកទឹកចិត្ត
- មានសមត្ថភាពក្នុងការពិនិត្យអនុលោមភាពរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងឯកសារចាំបាច់របស់គណនេយ្យនិងសវនកម្ម
- មានបទពិសោធន៍ក្នុងការត្រួតពិនិត្យ ឬផ្នែកសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងការរៀបចំគ្រប់គ្រងទិន្នន័យក្រុមហ៊ុនគណនេយ្យ និងក្រុមហ៊ុនសវនកម្ម
- មានជំនាញក្នុងការរៀបចំ និងសម្របសម្រួលការងារសិក្ខាសាលា ឬបណ្តុះបណ្តាលផ្សេងៗ។

**គ. ឯកសារភ្ជាប់**

- ប្រវត្តិរូបសង្ខេប
- សញ្ញាបត្រថតចម្លងដោយមានការបញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច
- អត្តសញ្ញាណបណ្ណ ឬច្បាប់ចម្លងសំបុត្រកំណើតឬ សៀវភៅគ្រួសារ (បញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច)
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារចេញដោយនិយោជក
- លិខិតថ្កោលទោសដែលនៅមានសុពលភាព (ក្រោយជាប់ជាស្ថាពរ)។

**២.ការជ្រើសរើស**

ការជ្រើសរើសត្រូវធ្វើឡើងតាមរយៈការធ្វើតេស្តសមត្ថភាពលើវិញ្ញាសាសរសេរ និងការសម្ភាសន៍ផ្ទាល់មាត់ពីគណៈកម្មការជ្រើសរើស។

*មានតែបេក្ខជន បេក្ខនារី ដែលត្រូវបានជាប់ដំណាក់កាលសម្រាំង (shortlisted Candidates) ប៉ុណ្ណោះ ដែលអាចចូលរួមធ្វើតេស្តលើវិញ្ញាសាសរសេរបាន ហើយមានតែបេក្ខជន បេក្ខនារី ដែលប្រឡងជាប់លើវិញ្ញាសាសរសេរប៉ុណ្ណោះ ទើបអាចចូលរួមធ្វើតេស្តសមត្ថភាពលើការសម្ភាសន៍ផ្ទាល់មាត់បាន។*

**៣.ការដាក់ពាក្យស្នើជ្រើសរើស**

បេក្ខជន បេក្ខនារី ត្រូវបំពេញពាក្យសុំចូលប្រឡងដែលអាចរកបាននៅតំណភ្ជាប់លើ (QR code) និងត្រូវមកដាក់ពាក្យស្នើសុំសិទ្ធិប្រឡងនៅ**និយ័តករគណនេយ្យនិងសវនកម្ម** ន.គ.ស. **អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដែលមានអាសយដ្ឋានផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ***ចាប់ពីការផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥ វេលាម៉ោង ៤ :០០នាទីរសៀល។***

ចំពោះកាលបរិច្ឆេទប្រឡង និងបញ្ជីរាយនាមបេក្ខជន បេក្ខនារី គណៈកម្មការជ្រើសរើសនឹងបិទផ្សាយនៅន.គ.ស. **អគារ "ក" ជាន់ទី១ នៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងនៅលើទំព័រ Facebook Page, Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ ០២៣ ៨៨២ ១១១, ០៧០ ២៩ ២៩ ៧១។

**និយ័តករគណនេយ្យនិងសវនកម្ម**

សម្គាល់៖ ពាក្យសុំប្រឡង បេក្ខជន បេក្ខនារី
អាចទាញយកបានតាមរយៈ QR Code ខាងក្រោម